ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥២ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួង
# ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍/



www.pheakdeylaw.com

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ អន្លង់វែង ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **ស៊ុំ តិរិទ្ធ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម **ជា មូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥- ឯកឧត្តម **តន់ វ៉ាន់ថារ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | អនុប្រធាន |
| ៦- ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៧- ឯកឧត្តម **ហាប់ អូម៉ាលី** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៨- ឯកឧត្តម **យស់ ឆោមណារ៉ាឌី** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៩- ឯកឧត្តម **ហ៊ឹ ទីរៈ** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ១០- លោក **លៀម សុជា** | អភិបាលរងខេត្តឧត្តរមានជ័យ | អនុប្រធាន |
| ១១- ឯកឧត្តម **ស្មើន សុខុម** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២- ឯកឧត្តម **ឌុប សុភ័ក** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៣- ឯកឧត្តម **ឈោប សាមុត** | អគ្គនាយកទេសចរណ៍ក្រសួងទេសចរណ៍ | សមាជិក |
| ១៤- ឯកឧត្តម **គង់ សុលីដា** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងទេសចរណ៍ | សមាជិក |
| ១៥- ឯកឧត្តម **ហាក់ ប៊ុណ្ណាក់** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្មនិងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា | សមាជិក |
| ១៦- ឯកឧត្តម **ខាក់ ពិសិដ្ឋ** | ទីប្រឹក្សានិងជាអគ្គនាយករងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៧- លោក **ឡុង វណ្ណៈ** | អគ្គនាយករងទេសចរណ៍ក្រសួងទេសចរណ៍ | សមាជិក |
| ១៨- លោក **យឹម ឆាន់ណា** | អភិបាលស្រុកអន្លង់វែង | សមាជិក |
| ១៩- លោកស្រី **ធិននី មុនីរស្មី** | ប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ | សមាជិក |



www.pheakdeylaw.com

២០- លោក **ឆាំង យុ** នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា សមាជិក

២១- លោកបណ្ឌិត **លី សុខឃាង** ប្រធានក្រុមការងារផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ និងសាលាក្តីខ្មែរក្រហម សមាជិក

**ប្រការ២ .-**

គណៈកម្មការអន្តរក្រសួងនេះត្រូវធ្វើការជំរុញ រៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដើម្បីអនុវត្តឱ្យបានសម្រេចជោគជ័យ តាមអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ហើយគណៈកម្មការអន្តរក្រសួងនេះមានភារកិច្ចដូចតទៅ៖

- រៀបចំគម្រោងប្លង់មេក្នុងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងសម្រាប់អភិវឌ្ឍឱ្យទៅជារមណីយដ្ឋានទេសចរណ៍ដែលមានស្តង់ដា និងជាសារមន្ទីរហោលវាល
- ចុះសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រពិតនៅក្នុងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដើម្បីចងក្រងជាឯកសារសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍
- ប្រមូលភស្តុតាងដែលនៅសេសសល់យកមករក្សាទុក ដើម្បីរៀបចំដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរ
- រៀបចំសាងសង់ឡើងវិញ ទៅតាមលំនាំនិងរចនាបថដើមនូវរាល់សំណង់ដែលបានបាត់បង់
- ធ្វើការផ្សព្វផ្សាយដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិឱ្យបានទូលំទូលាយទាំងក្នុងនិងក្រៅប្រទេស
- ធ្វើការផ្សព្វផ្សាយដល់គ្រប់ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល ដើម្បីស្វែងរកប្រភពថវិកាជួយឧបត្ថម្ភគាំទ្រលើគម្រោងផែនការអភិវឌ្ឍ
- ធ្វើសិក្ខាសាលាក្នុងមួយឆ្នាំម្តងស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងទៅតាមជំនាញនីមួយៗដែលបានអនុវត្តកន្លងមក
- លើកគម្រោងជូនរាជរដ្ឋាភិបាល ដើម្បីធ្វើការសិក្សាបែងចែកអនុវត្តទៅតាមជំនាញ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជាប្រចាំជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ .-**

គណៈកម្មការនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅក្រសួងទេសចរណ៍ មានសិទ្ធិប្រើត្រារបស់ក្រសួងទេសចរណ៍ និងថវិការបស់ក្រសួងទេសចរណ៍។ លេខាធិការដ្ឋាននេះមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ណោប សាមុត** អគ្គនាយកទេសចរណ៍ក្រសួងទេសចរណ៍ ប្រធាន

២- លោក **ត្លុង វណ្ណា** អគ្គនាយករងទេសចរណ៍ក្រសួងទេសចណ៍ អនុប្រធានអចិន្ត្រៃយ៍

៣- លោក **ជុក ជំនោរ** ប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌និងរមណីយដ្ឋានក្រសួងទេសចរណ៍ អនុប្រធាន



www.pheakdeylaw.com

៤- លោក **ស្រ៊ន សុវណ្ណារ៉ា** អនុប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌និង
រមណីយដ្ឋានក្រសួងទេសចរណ៍ សមាជិក

៥- លោក **កែន សុភី** អនុប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌
និងរមណីយដ្ឋានក្រសួងទេសចរណ៍ សមាជិក

៦-លោក **ហេង សុជាតិ** អនុប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
ក្រសួងទេសចរណ៍ សមាជិក

៧- លោក **លីម វណ្ណហេង** អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចណ៍
ក្រសួងទេសចណ៍ សមាជិក

៨- លោកស្រី **ធិនធី មុនីរស្មី** ប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ សមាជិក

៩- លោក **អឿន ធារិទ្ធ** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍
ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១០-លោក **ហេង កំសាន្ត** អនុប្រធាននាយកដ្ឋានបុរាណវិទ្យានិងបុរេប្រវត្តិវិទ្យា
ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

១១-លោក **ចាច់ សុវណ្ណា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងនិងអភិរក្សធនធានទឹក
ក្រសួងធនធានទឹកនិងឧតុនិយម សមាជិក

១២- លោក **ឈឹម សុខជិន** អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
ក្រសួងទេសចរណ៍ សមាជិក

១៣- លោក **សុគន្ធ ណារ៉ុង** អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ក្រសួងទេសចរណ៍ សមាជិក

**លេខាធិការដ្ឋាននេះមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖**

- ជាជំនួយការដល់គណៈកម្មការដើម្បីរៀបចំអភិវឌ្ឍនិងគ្រប់គ្រងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង
- សហការជាមួយស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីធ្វើការសិក្សាស្រាវជ្រាវប្រវត្តិតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង
- ស្រាវជ្រាវស្វែងរកភស្តុតាងប្រវត្តិសាស្ត្រទាំងអស់ ដើម្បីរៀបចំជាសារមន្ទីរប្រវត្តិសាស្ត្រអន្លង់វែង
- ធ្វើរបាយការណ៍លទ្ធផលការងារជូនប្រធានគណៈកម្មការ
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការប្រគល់ជូន។

**ប្រការ៤ .-**

គណៈកម្មការអន្តរក្រសួងនេះអាចរៀបចំបង្កើតក្រុមការងារបន្ថែមតាមការចាំបាច់ ដោយមានការយល់ព្រមពីប្រធានគណៈកម្មការ។



www.pheakdeylaw.com

**ប្រការ៥ ._**

សមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងអាចប្រើមន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមតាមសំណូមពរនិងទំហំការងារជាក់ស្តែង។

**ប្រការ៦ ._**

គណៈកម្មការអន្តរក្រសួងមានសិទ្ធិស្វែងរកដៃគូឯកជនឬអង្គការមិនមែនរដ្ឋាភិបាលដើម្បីជួយទ្រទ្រង់ដល់ដំណើរការអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង។

**ប្រការ៧ ._**

សេចក្តីសម្រេចលេខ៤៨ សសរ. ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ១និងប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ